# កម្មវិធីឃ្លាំមើលសវនាការសាលាក្តីខ្មែរក្រហម




**Asian International Justice Initiative (AIJI), a project of East-West Center and the WSD Handa Center for Human Rights and International Justice at Stanford University (previously known as the UC Berkeley War Crimes Studies Center)**

# របាយការណ៍សង្ខេបប្រចាំសប្តាហ៍ លេខ ៣១

នាសប្តាហ៍នេះ អង្គជំនុំជម្រះសាលាដំបូង បានបន្តកិច្ចដំណើរការនីតិវិធីសវនាការលើផ្នែកជំនុំជម្រះថ្មីស្តីពីការប្រព្រឹត្តចំពោះជនជាតិភាគតិចចាម ដោយស្តាប់សក្ខីកម្មរបស់សាក្សីចំនួនបួនរូប ពាក់ព័ន្ធនឹងការកំណត់ក្រុមគោលដៅ នៅក្នុងស្រុកកងមាស ខេត្តកំពង់ចាម។ ប្រធានបទនេះ មានលក្ខណៈខុសគ្នាទៅនឹងព្រឹត្តិការណ៍នៅក្នុងស្រុកក្រូចឆ្មារ ដែលត្រូវបានពិភាក្សាដេញដោលកាលពីសប្តាហ៍មុន ហើយការផ្តល់សក្ខីកម្មភាគច្រើនបានផ្តោតជាសំខាន់ជុំវិញការសម្លាប់រង្គាលមកលើជនជាតិចាមនៅក្នុងវត្តអូរត្រកួន ដែលបានក្លាយជាមន្ទីរសន្តិសុខនៅក្រោមរបបខ្មែរក្រហម។ សាក្សី និងដើមបណ្តឹងរដ្ឋប្បវេណី ក៏បានលើកឡើងផងដែរពីក្រុមដាវវែង ដែលត្រូវបានបង្កើតឡើងដើម្បីគ្រប់គ្រងមន្ទីរសន្តិសុខនោះ បន្ទាប់ពីកងកម្លាំងភូមិភាគនិរតីបានមកកាន់កាប់ក្នុងតំបន់នោះនៅដើមឆ្នាំ១៩៧៧។ នាសប្តាហ៍នេះ ភាគីទាំងអស់ក៏បានលើកឡើងពីការជំទាស់ជាច្រើនផងដែរ ពាក់ព័ន្ធនឹងភាពអាចទទួលយកបាននៃឯកសារ ការកំណត់សក្ខីកម្មរបស់សាក្សី វិសាលភាពនៃការជំនុំជម្រះ និងការប្រើប្រាស់សំណួរដែលមានលក្ខណៈច្រំដែល នាំមុខ និងប៉ាន់ស្មាន។ ទោះបីជាយ៉ាងនេះក្តី អង្គជំនុំជម្រះសាលាដំបូងបានគ្រប់គ្រងកិច្ចដំណើរការនីតិវិធីសវនាការប្រកបដោយប្រសិទ្ធភាព ដោយបានស្តាប់សក្ខីកម្មយ៉ាងច្រើនក្នុងអំឡុងពេលបួនថ្ងៃនៅសប្តាហ៍នេះ។

* របាយការណ៍នេះ ត្រូវបានសរសេរដោយ ចូឌីស កាយសើ (Judith Kaiser), ចយ ស្កុត (Joy Scott), ដាញៀល ម៉ាតថេស៍ (Daniel Mattes), តាយ លីណា, ភីនីឡូភី វ៉ាន់ ធូល (Penelope Van Tuyl) និង វង្ស ឧត្តម ដែលជាផ្នែកមួយនៃកម្មវិធីឃ្លាំមើលសវនាការសាលាក្តីខ្មែរក្រហម និងការផ្សព្វផ្សាយតាមសហគមន៍ របស់អង្គការគម្រោងផ្តួចផ្តើមយុត្តិធម៌អន្តរជាតិប្រចាំអាស៊ី (AIJI)។ AIJI គឺជាគម្រោងកិច្ចសហប្រតិបត្តិការរវាងមជ្ឈមណ្ឌលបស្ចិម-បូព៌ា (East-West Center) នៅអូណូឡូឡូ (Honolulu) និងមជ្ឈមណ្ឌល ដាប់ប៊ែលយូ.អេស.ឌី ហាន់ដា សម្រាប់សិទ្ធិមនុស្ស និង យុត្តិធម៌អន្តរជាតិ (WSD Handa Center) ដែលកាលពីមុន ត្រូវបានគេស្គាល់ថាជា មជ្ឈមណ្ឌលសិក្សាអំពីឧក្រិដ្ឋកម្មសង្គ្រាម ប៊ែកឃ្លី (Berkeley War Crime Study Center)។ ចាប់តាំងពីឆ្នាំ២០០៣មក មជ្ឈមណ្ឌលទាំងពីរនេះ បានកំពុងធ្វើកិច្ចសហប្រតិបត្តិការគ្នាលើគម្រោងជាច្រើន ដែលពាក់ព័ន្ធនឹងការបង្កើតការផ្តួចផ្តើមយុត្តិធម៌ និងកម្មវិធីកសាងសមត្ថភាពនានាក្នុងវិស័យសិទ្ធិមនុស្សប្រចាំតំបន់អាស៊ីអាគ្នេយ៍នេះ។

EAST-WEST CENTER

AIJI TRIAL MONITORING

WSDHANDACENTER
FOR HUMAN RIGHTS & INTERNATIONAL JUSTICE
Stanford University